**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មការមូលបត្រកម្ពុជា**
លេខ: ០០៥/១៦ គ.ម.ក./ប្រ.ក.

# ប្រកាស
# ស្តីពី
# វិនិយោគិនគុណវុឌ្ឍិក្នុងវិស័យមូលបត្រ

* * * * *

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៤១៦/៣៦៨ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលាឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា ទូរសព្ទ : ៨៥៥-២៣-៨៨៥-៦១១ ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Temporary Address: #99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia
Phone : 855-23-885-611 Fax : 855-23-885-622
[illegible] Website: [illegible]

- បានឃើញប្រកាសលេខ ០០៥/១៥ គ.ម.ក/ប្រ.ក. ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៦

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.- គោលបំណង**

ប្រកាសនេះមានគោលបំណងកំណត់លក្ខខណ្ឌ និងនីតិវិធីសម្រាប់វិនិយោគិនគុណវុឌ្ឍិដើម្បីចូលរួមក្នុងនីតិវិធីចាំបាច់ផ្សេងៗនៃការបោះផ្សាយលក់មូលបត្រជាសាធារណៈ និង/ឬការជូញដូរមូលបត្រដោយអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជននិងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

**ប្រការ ២.- និយមន័យ**

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់នៅក្នុងប្រកាសនេះត្រូវបានកំណត់នៅក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

-ច្បាប់ សំដៅដល់ច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន។

-អនុក្រឹត្យ សំដៅដល់អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន។

-វិនិយោគិនគុណវុឌ្ឍិ សំដៅដល់វិនិយោគិនជារូបវន្តបុគ្គល និងនីតិបុគ្គលដែលបំពេញលក្ខខណ្ឌទទួលបានគុណវុឌ្ឍិតាមប្រកាសនេះ។

-វិនិយោគិនស្ថាប័ន សំដៅដល់វិនិយោគិនជានីតិបុគ្គលដែលមានជំនាញ (Professionals) ក្នុងការវិនិយោគក្នុងវិស័យមូលបត្រ ដូចមានចែងក្នុងកថាខណ្ឌទី២ នៃប្រការ ៣ នៃប្រកាសនេះ ។

-វិនិយោគិនធនវុឌ្ឍិ សំដៅដល់វិនិយោគិនជារូបវន្តបុគ្គល និងនីតិបុគ្គល ដែលត្រូវបំពេញលក្ខខណ្ឌដូចមានចែងក្នុងកថាខណ្ឌទី៣ នៃប្រការ ៣ នៃប្រកាសនេះ។

-ទ្រព្យសកម្មសុទ្ធ សំដៅដល់ទ្រព្យដែលបានមកពីទ្រព្យសកម្មសរុបដកបំណុលសរុប។

## ជំពូកទី ២
## លក្ខខណ្ឌនៃវិនិយោគិនគុណវុឌ្ឍិ

**ប្រការ ៣.- លក្ខខណ្ឌជាវិនិយោគិនគុណវុឌ្ឍិ**

វិនិយោគិនគុណវុឌ្ឍិត្រូវមានលទ្ធភាពសមស្របក្នុងការវិភាគ និងធ្វើការសម្រេចចិត្តវិនិយោគក្នុងវិស័យមូលបត្រដោយត្រូវបំពេញលក្ខខណ្ឌដូចមានចែងក្នុងប្រកាសនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។ វិនិយោគិនគុណវុឌ្ឍិអាចជាវិនិយោគិនស្ថាប័ន ឬវិនិយោគិនធនវុឌ្ឍិ។

វិនិយោគិនគុណវុឌ្ឍិដែលជាវិនិយោគិនស្ថាប័ន (Institutional investor) រួមមាន÷

១-ធនាគារជាតិនៃកម្ពុជា។

២-ក្រុមហ៊ុនមូលបត្រ និងក្រុមហ៊ុនទីប្រឹក្សាវិនិយោគ ដែលទទួលបានអាជ្ញាបណ្ណពី គ.ម.ក.។

៣-ក្រុមហ៊ុនធ្វើអាជីវកម្មលើគម្រោងវិនិយោគរួម ដែលទទួលបានអាជ្ញាបណ្ណពី គ.ម.ក.។

៤-គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដែលទទួលបានអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា។

៥-ក្រុមហ៊ុនធានារ៉ាប់រងដែលទទួលបានអាជ្ញាបណ្ណពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

៦-បេឡាជាតិរបបសន្តិសុខសង្គម បេឡាជាតិអតីតយុទ្ធជន មូលនិធិជនពិការ បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល។

៧-ស្ថាប័នហិរញ្ញវត្ថុបរទេសដែលអនុញ្ញាតដោយអគ្គនាយកនៃ គ.ម.ក.។

៨-មូលនិធិអភិវឌ្ឍន៍នៃស្ថាប័នហិរញ្ញវត្ថុដែលអនុញ្ញាតដោយអគ្គនាយកនៃ គ.ម.ក.។

៩-នីតិបុគ្គលដទៃទៀតដែលអនុញ្ញាតដោយអគ្គនាយកនៃគ.ម.ក.។

វិនិយោគិនគុណវុឌ្ឍិដែលជាវិនិយោគិនធនវុឌ្ឍិ ( High Net-Worth) រួមមាន÷

១-នីតិបុគ្គលត្រូវមាន÷

- មូលធនភាគហ៊ុនិកសរុបយ៉ាងតិច ២.០០០.០០០.០០០ (ពីរពាន់លាន) រៀលដែលមានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុចុងក្រោយ ឬ
- ចំណូលប្រចាំឆ្នាំយ៉ាងតិច ៥០០.០០០.០០០ (ប្រាំរយលាន) រៀល ក្នុងរយៈពេល ២ (ពីរ)ឆ្នាំចុងក្រោយ ឬ
- ការចូលរួមវិនិយោគក្នុងវិស័យមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា យ៉ាងតិច ២០០.០០០.០០០ (ពីររយលាន) រៀល។

២-រូបវន្តបុគ្គល រាប់បញ្ចូលទាំងទ្រព្យរបស់សហព័ទ្ធ (ប្រសិនបើមាន) ត្រូវមាន÷

- ទ្រព្យសកម្មសុទ្ធសរុបយ៉ាងតិច ១.០០០.០០០.០០០ (មួយពាន់លាន) រៀល ឬ
- ចំណូលប្រចាំឆ្នាំយ៉ាងតិច ៨០.០០០.០០០ (ប៉ែតសិបលាន) រៀល ឬ
- ការចូលរួមវិនិយោគក្នុងវិស័យមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា យ៉ាងតិច ១០០.០០០.០០០ (មួយរយលាន) រៀល។

**ប្រការ ៤.- នីតិវិធីសម្រាប់វិនិយោគិនគុណវុឌ្ឍិ និងកាតព្វកិច្ចរបស់ក្រុមហ៊ុនមូលបត្រ**

ករណីវិនិយោគិនស្ថាប័ន វិនិយោគិនត្រូវផ្តល់ឯកសារបញ្ជាក់អត្តសញ្ញាណ និងឯកសារពាក់ព័ន្ធទៅក្រុមហ៊ុនមូលបត្រដើម្បីពិនិត្យផ្ទៀងផ្ទាត់។

ករណីវិនិយោគិនមានបំណងទទួលបានគុណវុឌ្ឍិជាវិនិយោគិនធនវុឌ្ឍិ តាមលក្ខខណ្ឌដូចចែងក្នុងកថាខណ្ឌទី៣ នៃប្រការ ៣ ខាងលើវិនិយោគិន ត្រូវបំពេញបែបបទតាមទម្រង់ដែលទទួលបានការអនុញ្ញាតពីអគ្គនាយកនៃ គ.ម.ក. របស់ក្រុមហ៊ុនមូលបត្រដោយភ្ជាប់មកជាមួយនូវភស្តុតាងបញ្ជាក់ ឬលិខិតប្រកាសអះអាង និងឯកសារភ្ជាប់ពាក់ព័ន្ធផ្សេងទៀតដូចជា របាយការណ៍ធនាគារ របាយការណ៍វិនិយោគចេញដោយក្រុមហ៊ុនមូលបត្រ វិញ្ញាបនបត្របញ្ជាក់ពីប្រាក់បញ្ញើ របាយការណ៍វាយតម្លៃទ្រព្យ ឯកសារចំណូល-ចំណាយ។

ក្រុមហ៊ុនមូលបត្រត្រូវត្រួតពិនិត្យដោយប្រុងប្រយ័ត្នលើភាពត្រឹមត្រូវលក្ខខណ្ឌ និងព័ត៌មានទាំងឡាយរបស់វិនិយោគិនទៅតាមច្បាប់ និងបទប្បញ្ញត្តិជាធរមានដើម្បីបញ្ជាក់ជាវិនិយោគិនគុណវុឌ្ឍិ។

ក្រុមហ៊ុនមូលបត្រត្រូវផ្តល់បញ្ជីឈ្មោះវិនិយោគិនគុណវុឌ្ឍិ និងឯកសារបញ្ជាក់ពាក់ព័ន្ធជូន គ.ម.ក. ទៅតាមនីតិវិធីកំណត់ថ្លៃមូលបត្រ ឬនីតិវិធីផ្សេងទៀតដែលតម្រូវ ឬតាមការតម្រូវរបស់អគ្គនាយកនៃ គ.ម.ក. ដើម្បីពិនិត្យផ្ទៀងផ្ទាត់តាមនីតិវិធី។

**ប្រការ ៥.- ការរក្សាទុកឯកសារ**

ក្រុមហ៊ុនមូលបត្រត្រូវរក្សាទុកនូវកំណត់ត្រា ឬឯកសារពាក់ព័ន្ធរបស់វិនិយោគិនគុណវុឌ្ឍិក្នុងវិស័យមូលបត្រក្នុងរយៈពេលយ៉ាងតិច ១០(ដប់) ឆ្នាំ។

## ជំពូកទី ៣
## ទោសប្បញ្ញត្តិ

**ប្រការ ៦.- វិធានការរដ្ឋបាល**

អគ្គនាយកនៃ គ.ម.ក. មានសិទ្ធិព្រមាន ដឹកនាំកែតម្រង់ ដាក់កំហិត ព្យួរ ឬដកហូតអាជ្ញាបណ្ណ ករណីក្រុមហ៊ុនមូលបត្រប្រព្រឹត្តល្មើសនឹងលក្ខខណ្ឌណាមួយនៃប្រកាសនេះ។

## ជំពូកទី ៤
## អវសានប្បញ្ញត្តិ

**ប្រការ ៧.- គោលការណ៍ណែនាំផ្សេងៗ**

គ.ម.ក. អាចចេញគោលការណ៍ណែនាំដើម្បីសម្រួលដល់ការយល់ដឹង និងការអនុវត្តតាមលក្ខខណ្ឌនៃប្រកាសនេះដល់បុគ្គលពាក់ព័ន្ធអ្នកចូលរួមក្នុងទីផ្សារមូលបត្រ និងដល់សាធារណជន។

**ប្រការ ៨.- ការអនុវត្ត**

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ នាយកដ្ឋាន អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា និងបុគ្គលពាក់ព័ន្ធត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែសីហាឆ្នាំ២០១៦

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុនសែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ ៨ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ